# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៤៨៥

ចុះថ្ងៃទី ០៧_០៧_២០១០

សាលដីកា

លេខ : ០៨ "ក្រ.III.ស"

ចុះថ្ងៃទី ២៤_០១_២០១២

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៦_០១_២០១២ ដោយមានសមាសភាពដូចខាងក្រោម:

<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

<u>តំណាងមហាអយ្យការ</u>

ឯកឧត្តម [redacted]

<u>ក្រឡាបញ្ជី</u>

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៤៨៥ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០១០ ដែលមាន:

១- ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ ឆែប ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ កើតនៅភូមិជប់ព្រីង ឃុំកំពង់រោទិ៍ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ទីលំនៅមុន[redacted] ខណ្ឌមានជ័យ រាជធានីភ្នំពេញ មុខរបរកម្មករ ឪពុកឈ្មោះ [redacted](រ) ម្ដាយឈ្មោ[redacted] (ស) នៅលីវ ទោសពីមុនគ្មាន ឃាត់ខ្លួនថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៨ ឃុំខ្លួនថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ (ដើមបណ្ដឹងឧទ្ធរណ៍) ។

មានលោក [redacted]ចន្ថា ជាមេធាវីការពារ ។

២- ជនជាប់ចោទឈ្មោ[redacted]សុភ័ក្រ ហៅ កែវ ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់ផ្សារដេប៉ូ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅមុនពេលចាប់[redacted] សង្កាត់ ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មុខរបរកម្មករ ឪពុកឈ្មោះ[redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់ ទោសពីមុនគ្មាន ឃាត់ខ្លួនថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៨ ឃុំខ្លួនថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ (ដើមបណ្ដឹងឧទ្ធរណ៍) ។

មានលោក[redacted] ចន្ថា ជាមេធាវីការពារ ។ ៚



Scanned with CamScanner

**ជាប់ចោទពីបទៈ** ប្លន់ ប្រព្រឹត្តនៅផ្ទះលេខ ៣០ ផ្លូវ ៤៩៤ ក្រុមទី ១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ភារុន** ភេទប្រុស អាយុ ២៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៣០ ផ្លូវ ៤៩៤ ក្រុមទី ១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

- តាមសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] **សុភ័ក្រ** និងឈ្មោះ [redacted] **រតនា** ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ៣ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។។

**ដំណើររឿងមានដូចតទៅ:**

កាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៨ វេលាម៉ោងប្រហែល ២៣យប់ ជនរងគ្រោះឈ្មោះ [redacted] ភារុន បានទុកម៉ូតូម៉ាកហ៊ីណ្ឌពណ៌ខ្មៅលាយសនៅក្នុងផ្ទះលេខ ៣០ ផ្លូវ ៤៩៤ ក្រុមទី ១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយបានចាក់សោទុកត្រឹមត្រូវរួចក៏ចូលដេក លុះដល់ព្រឹកឡើង វេលាម៉ោង ៦ព្រឹក ពេលងើបពីដំណេកឡើងក៏បាត់ម៉ូតូ មានស្នាមគាស់ទ្វារផ្ទះឡើងរបើក។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ៣ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:**

១/- ផ្តន្ទាទោស

- ឈ្មោះ [redacted] **រតនា ហៅ នៃប** ភេទប្រុស អាយុ ២២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ ភូមិជប់ព្រីង ឃុំកំពង់រោទិ៍ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ទីលំនៅមុន [redacted] ខណ្ឌមានជ័យ រាជធានីភ្នំពេញ មុខរបរកម្មករ នៅលីវ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន។

- ឈ្មោះ [redacted] **សុភ័ក្រ ហៅ កែវ** ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដេប៉ូ ខណ្ឌទួលគោក រាជធានីភ្នំពេញ អាស័យដ្ឋា[redacted] សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ៦ឆ្នាំ (ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ពីបទ ប្លន់ ប្រព្រឹត្តនៅផ្ទះលេខ ៣០ ផ្លូវ ៤៩៤ ក្រុមទី ១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- ឈ្មោះ [redacted] **ប៊ុនអេង ហៅ ម៉ាប់** ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ មុខរបររត់ម៉ូតូឌុប ទីកន្លែងកំណើតនៅភូមិទងត្រឡាច ឃុំទងត្រឡាច ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ទីលំនៅមុន [redacted]



Scanned with CamScanner

មានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (ស) ម្ដាយឈ្មោះ[redacted](រ) ប្រពន្ធឈ្មោះ[redacted] មានកូន ២នាក់ ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារកំណត់ ១៨ខែ (ដប់ប្រាំបីខែ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០០៨ ពីបទ **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២- ទុកសិទ្ធិឱ្យជនរងគ្រោះប្ដឹងទាមទារសំណងរដ្ឋប្បវេណីនៅពេលក្រោយ។

៣- ប្រគល់ម៉ូតូតាមកំណត់ហេតុប្រគល់ម៉ូតូបណ្ដោះអាសន្នរបស់ការិយាល័យកម្រិតស្រាល ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៨ ឱ្យម្ចាស់ដើមវិញ។

៤- ប្រគល់ម៉ូតូតាមកំណត់ហេតុទទួលវត្ថុតាងលេខ ១៤០ អយធ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៨ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឱ្យម្ចាស់ដើមវិញ។

៥- សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៩ ប្រកាសជាសាធារណៈ នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] **រតនា**, [redacted] **សុភ័ក្រ**, [redacted] **ប៊ុនអេង** មេធាវីការពារជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted] សុភ័ក្រ និងឈ្មោះ [redacted] រតនា ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ៣ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

**<u>នាពេលសវនាការ</u>**

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ភារុន** បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ជនជាប់ចោទឈ្មោះ[redacted] **រតនា** ឆ្លើយថាៈ ខ្លួនប្ដឹងឧទ្ធរណ៍មក ដើម្បីឱ្យសាលាឧទ្ធរណ៍បន្ធូរបន្ថយទោសឱ្យខ្លួន។ ខ្លួនពិតជាបានប្រព្រឹត្តមែន ខ្លួនបានចូលទៅយកម៉ូតូ ព្រោះទ្វារដាក់គន្លឹះពុំមានចាក់សោរទេ ខ្លួនបានឆ្កឹះគន្លឹះទ្វារ ហើយយកម៉ូតូបានជិះដើរលេងសិន រួចឱ្យឈ្មោះ **ភ័ក្រ** យកទៅលក់បាន ៦៣០ដុល្លារអាមេរិក យកចាយវាយ។ នៅថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០០៨ ខ្លួនទៅម្នាក់ឯង ខ្លួនអត់បានទម្លុះទម្លាយទ្វារទេ គឺខ្លួនឆ្កឹះសោរ ម៉ូតូនៅក្នុងផ្ទះ ហើយម៉ូតូអត់ចាក់សោរ ទេ សោរម៉ូតូនៅជាប់ម៉ូតូ ពេលយកម៉ូតូបាន ស្អែកឡើងខ្លួនជួប **ភ័ក្រ** ជូនទៅលក់ម៉ូតូ ខ្លួនកាត់ ៨០០ដុល្លារ តែលក់បាន ៦៣០ដុល្លារ ហើយឱ្យទៅឈ្មោះ **ម៉ាប់** ខ្លួនបានថែម ៣០០ដុល្លារ ទៀត ហើយទិញម៉ូតូ ១ទៀត មិនមានអ្នកណាចូលរួមទេ ពេលយកម៉ូតូ។ ៥



Scanned with CamScanner

ជនជាប់ចោទឈ្មោះ [redacted] សុភ័ក្រ្ត ឆ្លើយថាៈ នៅថ្ងៃកើតហេតុខ្លួនចេញមកពីខារ៉ាអូខេផឹកជាមួយពួកម៉ាក ពេលចេញមកជួប **រតនា** នៅស្ទឹងមានជ័យ ហើយ **រតនា** បានបបួលខ្លួនឱ្យជូនទៅលក់ម៉ូតូ។ អ្វីដែល **រតនា** រៀបរាប់ជាការពិត ខ្លួនមិនបានចូលទៅលួចទេ ពេលបបួលខ្លួនទៅលក់ម៉ូតូ ខ្លួនអត់ដឹងថា ម៉ូតូ **រតនា** លួចគេទេ។ ពេលនោះខ្លួនស្រវឹងស្រា ហើយខ្លួនមិនបានសួរទេ ថា ម៉ូតូបានមកពីណា។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

សាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ៣ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចមកនេះគួរតម្កល់ទុកជាបានការ ដោយគ្រាន់តែកែបទចោទលើឈ្មោះ [redacted] រតនា មកជាបទ លួចមានស្ថានទម្ងន់ទោស តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ហើយ និងលើឈ្មោះ [redacted] សុភ័ក្រ្ត មកជាបទ អ្នកសមគំនិតក្នុងបទលួចមានស្ថានទម្ងន់ទោស តាមមាត្រា ២៩ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ឆ្លងតាមការស្តាប់របាយការណ៍ ការស្តាប់សន្និដ្ឋាន និងការសួរដេញដោលពេលនេះនៅចំពោះសវនាការ ឈ្មោះ ភ័ក្រ្ត និងឈ្មោះ **រតនា** ក៏បានថា ខ្លួនមិនបានចូលទៅគាស់ផ្ទះទេ គឺបានចូលទៅតាមទ្វារក្រោយយកម៉ូតូ ហើយឈ្មោះ ភ័ក្រ្ត ថា ខ្លួនមិនបានចូលរួមទេ គឺគ្រាន់តែបានជួយលក់ម៉ូតូឱ្យឈ្មោះ **រតនា** ប៉ុណ្ណោះ។ ធាតុពិតជនរងគ្រោះនៅក្នុងសំណុំរឿងមិនបានចូលមកឆ្លើយដែរ. បើ **រតនា** គាស់ ជនរងគ្រោះគាត់សម្រាន្តនៅខាងក្រៅផ្ទះ ហេតុអីគាត់មិនដឹង។ ចំពោះកូនក្តីខ្លួនមិនប្រកែកទេ គ្រាន់តែសុំឱ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោស ព្រោះនេះជាការប្រព្រឹត្តលើកទី ១។ ចំពោះឈ្មោះ ភ័ក្រ្ត តំណាងអយ្យការបានចោទប្រកាន់ ពីបទ សមគំនិត គឺពុំត្រឹមត្រូវទេ ព្រោះឈ្មោះ ភ័ក្រ្ត នៅយប់កើតហេតុនៅក្នុងខារ៉ាអូខេ មិនបានចូលរួម ឬសមគំនិតក្នុងអំពើលួចនេះទេ គ្រាន់តែបានចូលរួមជូនទៅលក់ម៉ូតូប៉ុណ្ណោះ។ សុំកែបទចោទមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ទៅជាបទ ចោរកម្ម និងសុំបន្ធូរបន្ថយទោសលើឈ្មោះ **រតនា** និងឈ្មោះ ដួង **រតនា** តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ផង។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថាៈ

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] សុភ័ក្រ្ត និងឈ្មោះ [redacted] រតនា ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- ជនជាប់ចោទ [redacted] សុភ័ក្រ្ត បានឆ្លើយសារភាពថា [redacted] **រតនា** បានបបួលខ្លួនដើរផឹកស៊ីច្រៀងខារ៉ាអូខេ តែមិនបានប្រាប់ខ្លួនថា បានលក់ម៉ូតូមួយគ្រឿង និងធ្លាប់បបួលខ្លួនទៅទិញថ្នាំញៀនប្រើប្រាស់ម្តងម្កាលដែរ។



Scanned with CamScanner

៣- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ប៊ុនអេង ហៅ ម៉ាប់ ថា ខ្លួនពិតជាបានទិញម៉ូតូម៉ាក FINO ពណ៌ខ្មៅលាយស ពីឈ្មោះ [redacted] រតនា និង [redacted] សុភ័ក្រ្ត ដែលយកមកលក់ដល់ផ្ទះខ្លួនមែន។

៤- មានពិរុទ្ធលើជនជាប់ចោទ ពីបទ ប្លន់ ប្រព្រឹត្តនៅផ្ទះលេខ ៣០ ផ្លូវ ៤៩៤ ក្រុមទី ១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០០៨ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ៣ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] សុភ័ក្រ្ត និងឈ្មោះ [redacted] រតនា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ៣ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣- បង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១២ ប្រកាសជាសាធារណៈនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខតាមច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខ[redacted] | [redacted] | ហត្ថលេខា: [redacted] |

---

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី ០៤ ខែ ០៦ ឆ្នាំ ២០១៤
ក្រឡាបញ្ជី



Scanned with CamScanner